C4/42

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**អង្គបុរេជំនុំជម្រះ**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ០១)

**អង្គបុរេជំនុំជម្រះ**

នៅចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Kathinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២១ កុម្ភៈ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 03 / 2008
ម៉ោង (Time/Heure): 13 h 30 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

---

**ពាក្យសុំដាក់សារណារបស់អង្គការ THE REDRESS TRUST (REDRESS), ដែលជាសហព័ន្ធអន្តរជាតិនៃសិទ្ធិមនុស្ស (FIDH) និងអង្គការមេធាវីគ្មានព្រំដែន (ASF)**

**សារណាសាធារណៈ: ជនរបស់អ្នកដាក់សារណា**

---

<u>សហព្រះរាជអាជ្ញា</u>
ជា លាង
Robert PETIT

<u>ជនត្រូវចោទ</u>
នួន ជា

<u>មេធាវីខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី</u>
ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី

<u>សហមេធាវី</u>
សុន អារុណ
Michiel PESTMAN
Victor KOPPE

Original EN: 00164691-00164701

**អ្នកដាក់សារណា**

I- ភាគីដែលជាម្ចាស់សារណាសាធារណៈជននេះ មានបទពិសោធន៍យ៉ាងច្រើនក្នុងការជួយ និងធ្វើតំណាងឲ្យក្រុមបុគ្គល និងសហគមន៍ជាច្រើនដែលធ្លាប់បានទទួលរងគ្រោះពីអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។

i- អង្គការ The Redress Trust (REDRESS) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលមានមុខងារស្វែងរកយុត្តិធម៌ និងការសងជម្ងឺចិត្តជូនជនរងគ្រោះដែលបានទទួលរងទារុណ្ណកម្ម និងបទឧក្រិដ្ឋអន្តរជាតិ។ អង្គការ REDRESS មានជំនាញឯកទេសជាច្រើនខាងផ្នែកសិទ្ធិជនរងគ្រោះនៃអំពើទារុណ្ណកម្ម និងការរំលោភបំពានធ្ងន់ធ្ងរផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងច្បាប់ មនុស្សធម៌អន្តរជាតិ ដើម្បីឲ្យពួកគាត់អាចទទួលបានសេវាកម្មតុលាការ និងសំណងជម្ងឺចិត្តចំពោះទុក្ខវេទនារបស់ពួកគាត់។ អង្គការនេះបានធ្វើការតស៊ូមតិជំនួសឲ្យជនរងគ្រោះមកពីគ្រប់តំបន់នៃពិភពលោក។ លើសពីនេះទៅទៀត ខ្លួនមានឯកទេសយ៉ាងទូលំទូលាយខាងផ្នែកសិទ្ធិទទួលបានសំណងជម្ងឺចិត្តចំពោះជនរងគ្រោះនៃអំពើទារុណ្ណកម្មដែលមានចែងក្នុងច្បាប់អន្តរជាតិ ក្នុងនោះគឺរួមមានការរកលទ្ធភាពឲ្យជនរងគ្រោះបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងឡាយណាដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគាត់។ ជាប្រចាំ អង្គការនេះ ទទួលកាន់ករណីដែលមានកម្រិតថ្នាក់ជាតិ ឬអន្តរជាតិជំនួសមុខឲ្យបុគ្គលដែលនៅរស់រានមានជីវិត និងជួយដល់អ្នកតំណាងទាំងឡាយដែលដើរតួធ្វើជាតំណាងឲ្យពួកគាត់ទាំងអស់នោះ។ អង្គការ REDRESS មានបទពិសោធន៍លើសលុបក្នុងការប្រឡូកនៅចំពោះមុខតុលាការជាតិ អន្តរជាតិ និងសាលាក្តីនានាផងដែរ ដូចជាគណៈកម្មធិការអង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណ្ណកម្មនិងគណៈកម្មាធិការសិទ្ធិមនុស្ស, តុលាការសិទ្ធិមនុស្សអឺរ៉ុប, គណៈកម្មាការអន្តរអាមេរិកាំងដើម្បីសិទ្ធិមនុស្ស, តុលាការពិសេសនៃប្រទេសសេរ៉ាឡេអូន, និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ជាឧទាហរណ៍ជាក់ស្តែងអំពីការប្រឡូករបស់អង្គការ REDRESS គឺការដែលអង្គការនេះបានវិវឌ្ឍបទពិសោធន៍របស់ខ្លួនលើផ្នែកសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិនេះឯង។

ii- **សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស** (FIDH) គឺជាអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលមួយដែលមានមុខងារការពារសិទ្ធិមនុស្សដែលមានចែងក្នុងសេចក្តីប្រកាសសិទ្ធិមនុស្សជាសកល។ អង្គការ FIDH ជួយជាពិសេសដល់ជនរងគ្រោះនៃបទឧក្រិដ្ឋកម្មអន្តរជាតិ ប្រយោជន៍ធ្វើយ៉ាងណាធ្វើការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព ដើម្បីស្វែងរកការពិត យុត្តិធម៌ និងសំណងជម្ងឺចិត្តជូនដល់ជនរងគ្រោះ។ FIDH

ធ្វើការតស៊ូមតិដើម្បីឲ្យមាកការបញ្ញ្រាបបទដ្ឋានអន្តរជាតិស្តីពីការការពាររបស់សិទ្ធិជនរងគ្រោះនៃបទឧក្រិដ្ឋកម្មអន្តរជាតិ។ FIDH ក៏ចូលប្រឡូកក្នុងកិច្ចដំណើរការនីតិវិធី ការឈរធ្វើជាតំណាងឲ្យជនរងគ្រោះ ឬក៏ដើរតួក្នុងនាមខ្លួនឯងផ្ទាល់ផងដែរ។ ពេលបច្ចុប្បន្ននេះ FIDH កំពុងផ្តល់ជំនួយ និងធ្វើជាតំណាងផ្នែកច្បាប់ជូនដល់ជនរងគ្រោះ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលកំពុងតែដំណើរការចំនួន ២០ ករណីដែលពាក់ព័ន្ធទៅនឹងយុត្តាធិការសកល និងយុត្តាធិការក្រៅរង្វង់ដែនដីកំណត់ និងបានចូលរួមតាំងខ្លួនជា “ដើមបណ្តឹងរដ្ឋប្បវេណី” ក្នុងកិច្ចដំណើរការនីតិវិធីនៅប្រទេសបារាំង។ FIDH ក៏ជួយជនរងគ្រោះនៅចំពោះមុខស្ថាប័នសិទ្ធិមនុស្សប្រចាំតំបន់ (តុលាការសិទ្ធិមនុស្សអឺរ៉ុប, គណៈកម្មាការសិទ្ធិមនុស្សអន្តរអាមេរិកាំង) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ FIDH បានពង្រីកវិសាលភាពនៃឯកទេសដ៏ធំទូលាយរបស់ខ្លួនខាងផ្នែកសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់អន្តរជាតិ ដើម្បីឱ្យពួកគាត់អាចចូលរួមបានទាំងក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការជាតិ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។

iii- **មេធាវីគ្មានព្រំដែន (ASF)** ដែលមានទីស្នាក់ការធំនៅប្រទេសបែលហ្ស៊ិក គឺជាអង្គការអន្តរជាតិក្រៅរដ្ឋាភិបាលមួយដែលបង្កើតឡើងដោយមេធាវី និងអ្នកជំនាញផ្នែកច្បាប់។ បេសកកម្មឯករាជ្យរបស់អង្គការនេះគឺធ្វើយ៉ាងណាជួយបង្កើតឲ្យមានសង្គមយុត្តធម៌ និងស្មើភាពគ្នាមួយ ដែលមានច្បាប់ និង ស្ថាប័នច្បាប់បម្រើដល់ក្រុមមនុស្សដែលងាយរងគ្រោះឲ្យបានច្រើនបំផុត។ អង្គការនេះទទួលស្គាល់នូវវត្ថុបំណងនេះតាមរយៈការចូលប្រឡូកជាទូទៅក្នុងវិស័យតុលាការ និងជាពិសេសនោះគឺក្នុងវិស័យជំនួយផ្លូវច្បាប់ និងសេវាកម្មផ្នែកច្បាប់។ អង្គការ ASF មានគម្រោងរយៈពេលវែងរបស់ខ្លួននៅក្នុងប្រទេសរ៉ូវ៉ាន់ដា ប៊ូរុនឌី សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ អ៊ុយហ្គង់ដា និងទីម័រខាងកើត និងមានគម្រោងសំខាន់ៗស្រដៀងគ្នានេះមួយចំនួនទៀតដែលពាក់ព័ន្ធនឹងការបង្ការអំពើទារុណ្ណកម្ម, យុត្តិធម៌អន្តរជាតិ, សាកលភាវូនីយកម្មនៃយុត្តិធម៌។ កម្មវិធីយុត្តិធម៌អន្តរជាតិរបស់អង្គការ ASF ផ្តោតយ៉ាងខ្លាំងលើគោលការណ៍បំពេញបន្ថែមទៅលើលក្ខន្តិកៈក្រុងរ៉ូម តាមរយៈការកសាងសមត្ថភាពតួអង្គតុលាការជាតិ និងតួអង្គសង្គមស៊ីវិល ព្រមទាំងសកម្មភាពជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ និងការធ្វើជាតំណាងផ្នែកច្បាប់។ ASF ផ្តល់ការធ្វើជាតំណាងផ្នែកច្បាប់ទៅដល់ជនរងគ្រោះដំបូងគេបង្អស់ចំនួនបីរូបដែលបានអនុញ្ញាតឲ្យធ្វើជាភាគីក្នុងរឿងក្តីប្រឆាំងនឹង Thomas Dyilo Lubanga នៅឯតុលាការ

ព្រហ្មទណ្ឌអន្តរជាតិ។ ដោយសារតែរឿងនេះ ទើបធ្វើឱ្យមេធាវីរបស់អង្គការ ASF បានអភិវឌ្ឍជំនាញដ៏សំខាន់មួយទាក់ទងនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីនៃតុលាការ ICC។

**ការដាក់សារណាដូចមានចែងក្នុងវិធាន ៣៣ នៃវិធានផ្ទៃក្នុង**

១. អ្នកដាក់សារណាដាក់សារណានេះអនុលោមទៅតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង និងជាការឆ្លើយតបទៅនឹងសេចក្ដីបង្គាប់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ របស់អង្គបុរេជំនុំជម្រះវិសាមញ្ញ (C11/36) ដែល អញ្ជើញសាធារណៈជនឱ្យដាក់សារណា។ អ្នកដាក់សារណាគ្រាន់តែចង់បង្ហាញនូវការចាប់អារម្មណ៍ជា លាយលក្ខណ៍អក្សរប៉ុណ្ណោះ ហើយសេចក្ដីពិតនៃចំណាប់អារម្មណ៍នេះមានរៀបរាប់នៅក្នុងសារណាខាងក្រោមនេះឯង។

២. គោលបំណងនៃសារណានេះគឺចង់ជួយអង្គបុរេជំនុំជម្រះក្នុងការពិចារណាអំពីដើមចម និងវិសាលភាពនៃការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើការនីតិវិធី និងជាពិសេសក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធជាមួយនឹងបណ្ដឹងឧទ្ធរណ៍ទាំងឡាយប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ អ្នកដាក់សារណាត្រូវបានជ្រើសរើសសម្រាំងដើម្បីជួយអង្គបុរេជំនុំជម្រះដើម្បីអាចកំណត់ឱ្យបានត្រឹមត្រូវលើចំណុចដែលកំពុងមាននៅចំពោះមុខ អ.វ.ត.ក។ បទពិសោធន៍របស់ខ្លួនក្នុងការបានធ្វើការជាមួយជនរងគ្រោះទាំងឡាយដែលជាប្រភេទនៃជនរងគ្រោះនៃបទឧក្រិដ្ឋដូចមានក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរនោះ បានធ្វើឱ្យពួកខ្លួនមានការយល់ដឹងអំពីកង្វល់ជាទូទៅ និងទស្សនៈវិស័យដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចនឹងមាន នៅក្នុងដំណាក់កាលជាបន្តបន្ទាប់នៅក្នុងកិច្ចដំណើរការនីតិវិធី និងធ្វើឱ្យពួកខ្លួនស្ថិតក្នុងទីតាំងមួយដែលប្រសើរបំផុតដើម្បីអាចបង្ហាញជូន អ.វ.ត.ក នូវចំណុចដែលត្រូវពិចារណា និងគោលនយោបាយផ្នែកច្បាប់មួយចំនួនដែល អ.វ.ត.ក គួរតែដឹងជាមុនមុននឹងពិចារណាទៅលើបញ្ហានៃការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ បន្ថែមលើនេះទៀតដោយហេតុថា ម្ចាស់សារណាធ្លាប់មានបទពិសោធន៍និងជំនាញដែលគេទទួលស្គាល់ក្នុងវិស័យនៃការលើកកម្ពស់សិទ្ធិរបស់ជនរងគ្រោះក្នុងបរិបទជាតិ និងអន្តរជាតិ រួមមានតុលាការព្រហ្មទណ្ឌអន្តរជាតិផងនោះ ទើបធ្វើឱ្យពួកខ្លួនមានសមត្ថភាពពិសេសក្នុងការផ្ដល់ជូននៅការចាប់អារម្មណ៍ទាំងឡាយទៅដល់ អ.វ.ត.ក ស្ដីពីវិសាលភាព និងទំហំនៃសិទ្ធិក្នុងការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលជាសិទ្ធិដែលមានការទទួលស្គាល់ដោយច្បាប់ជាតិ និងការអនុវត្តន៍ និងដែលធ្លាប់អាចយកមកប្រើប្រាស់បានក្នុងបទដ្ឋានអន្តរជាតិ និងបទដ្ឋានតំបន់។ យុត្តិសាស្ត្រ និងការអនុវត្តន៍ដែលមានការពាក់ព័ន្ធ

និងបញ្ហានៃការចូលរួមរបស់ជនរងគ្រោះនៃបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់អន្តរជាតិនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ គឺមានវិសាលភាពហួសពីយុត្តិសាស្ត្រសាលាក្តីពិសេសទាំងឡាយ រហូតដល់វិស័យច្បាប់ព្រហ្មទណ្ឌជាតិ, និងការទាមទារសំណងរដ្ឋប្បវេណី, យុត្តាធិការសិទ្ធិមនុស្ស និងកិច្ចដំណើរការស៊ើបអង្កេតរដ្ឋបាល ទាំងនេះទៅទៀត។

៣. មានការលើកជាសំណើថា លទ្ធផលនៃការសម្រេចណាមួយដែលធ្វើឡើងដោយ អ.វ.ត.ក ស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីនេះនឹងពិតជាជះឥទ្ធិពលយ៉ាងធំធេងមិនមែនត្រឹមតែលើភាគីនានាក្នុងពេលឥឡូវនេះប៉ុណ្ណោះទេ។ ដូច្នេះដើម្បីជាការប្រពៃគោងតែអង្គបុរេជំនុំជម្រះទទួលបាននូវទស្សនៈទានប្លែកៗជាច្រើនដើម្បីជាជំនួយក្នុងការសម្រេចលើករណីនេះ។

**ចំណាប់អារម្មណ៍របស់ម្ចាស់សារណាក្នុងបញ្ហានៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

៤. បញ្ហានៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី និងជាពិសេសកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ លើកឡើងនូវបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងសិទ្ធិរបស់អត្ថគាហក(អ្នកទទួលផល)នៃ អ.វ.ត.ក ពោលគឺថាតើត្រូវធ្វើយ៉ាងណាដើម្បីឲ្យពួកគាត់មានប្រសិទ្ធិភាពក្នុងការទទួលបានសិទ្ធិនេះ។ ពិសេសទៅទៀតនោះគឺបញ្ហានេះវាគាស់កកាយឲ្យមានការបកស្រាយឲ្យបានត្រឹមត្រូវចំពោះវិធាន ២៣ នៃវិធានផ្ទៃក្នុង រួមទាំងលក្ខណៈ ការប្រតិបត្តិការ និងវិសាលភាពនៃសិទ្ធិចូលរួមក្នុងនីតិវិធីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យពួកគាត់អាចបង្ហាញនូវទស្សនៈ និងកង្វល់របស់ខ្លួនបាន។

៥. ម្ចាស់សារណាមានបំណងចង់ផ្តល់ជូន អ.វ.ត.ក នូវគំនិតយល់ឃើញដែលពាក់ព័ន្ធនឹងច្បាប់ និងយុត្តិសាស្ត្រនៃប្រទេសផ្សេងៗ ក៏ដូចជាយុត្តិសាស្ត្រដែលពាក់ព័ន្ធពីតុលាការអន្តរជាតិ និងបទដ្ឋានអន្តរជាតិទាំងឡាយដែលកំពុងអនុវត្ត។ ដោយសារតែសិទ្ធិចូលរួមក្នុងនីតិវិធីដែលទទួលស្គាល់ក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ ខុសគ្នាច្រើនពីសិទ្ធិដែលប្រគល់ទៅឲ្យជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្តីអន្តរជាតិផ្សេងៗទៀតនោះ គឺគ្មានអ្វីជាគំរូពិតប្រាកណាមួយដែលធ្លាប់បានអនុវត្តកន្លងមកជាលក្ខណៈអន្តរជាតិសម្រាប់ឲ្យ អ.វ.ត.ក យកធ្វើជាពំនាក់នោះឡើយ។ ម្ល៉ោះហើយដើម្បីជួយ អ.វ.ត.ក ក្នុងការពិចារណារបស់ខ្លួនលើបញ្ហានេះ ខ្លួនគួរតែប្រមូលយកមតិយោបល់ពីគ្រប់មជ្ឈដ្ឋាន។

**ចំណុចជាក់លាក់មួយចំនួនដែលម្ចាស់សារណាចង់ផ្តល់ជូនជាយោបល់**

៦. សារណានេះនឹងផ្តោតសំខាន់ទៅលើចំណុចជាក់លាក់មួយចំនួនដូចខាងក្រោម:

៦.១ លទ្ធភាពក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីពីដំបូងៗរបស់ អ.វ.ត.ក រួមមានកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជាគោលបំណងមួយដ៏សំខាន់ដែលស្របគ្នានឹងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

៦.២ លទ្ធភាពក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីពីដំបូងៗរបស់ អ.វ.ត.ក រួមមានកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺមានភាពស្របគ្នានឹងបទដ្ឋាន និងការអនុវត្តន៍របស់ជាតិ និងអន្តរជាតិ។

៦.៣ ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ មិនរំលោភសិទ្ធិការពារក្តីទេ។

**លទ្ធភាពក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីពីដំបូងៗ របស់ អ.វ.ត.ក រួមមានកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជាគោលបំណងមួយដ៏សំខាន់ដែល ស្របគ្នានឹងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក**

៧. មានការបញ្ជាក់យ៉ាងច្បាស់ទាំងក្នុងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ថាកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានការចូលរួមពីភាគីដើមបណ្តឹងរដ្ឋប្បវេណី។

៨. លទ្ធភាពសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើការនៃ អ.វ.ត.ក ត្រូវបានថែរក្សា និងការពារក្នុងវិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលមានចែងអំពីគោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បី:

"ក. ចូលរួមក្នុងដំណើការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទ ប្រកាន់ និង ខ. អនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព"។

៩. នេះបានន័យថា ការទទួលដែលជនរងគ្រោះទទួលឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះគឺត្រូវបានទទួលស្គាល់ ដោយអនុលោមតាមវិធាន ២៣(៦)(ក) ថាជាភាគីមួយក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌរួចទៅហើយ។ ការដែលទទួលបានឋានៈជា "ភាគី" ក្នុងកិច្ចដំណើរការនីតិវិធី (នៅចំពោះមុខ អ.វ.ត.ក ក៏ដូចជានៅចំពោះមុខតុលាការធម្មតារបស់កម្ពុជា) គឺផ្តល់នូវសិទ្ធិជាទូទៅដល់បុគ្គលទាំងឡាយដែលទទួលបានឋានៈនេះ។ សិទ្ធិនេះគឺមានផ្តល់ជូនជាទូទៅដល់ជនត្រូវចោទ ឬជនជាប់ចោទ[១]។

- នៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង និងនៅពេលមានការដាក់បណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជី "ត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីផ្សេងៗ និងបញ្ជូនច្បាប់ចម្លងនៃសារណាបណ្តឹងឧទ្ធរណ៍"។

- អនុលោមតាមវិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង នៅពេលដែលប្រធាននៃអង្គបុរេជំនុំជម្រះកំណត់កាលបរិច្ឆេទសវនាការ ក្រឡាបញ្ជីត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និងមេធាវីរបស់ភាគីទាំងនោះ។

- អនុលោមតាមវិធាន ៧៧(៤) នៃវិធានផ្ទៃក្នុង "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគី" អាចសុំមើលសំណុំរឿងរហូតដល់ថ្ងៃសវនាការ។ "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីត្រូវដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ ដូចមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទនៃការទទួលឯកសារ និងដាក់ឯកសារទាំងនោះចូលទៅក្នុងសំណុំរឿងភ្លាម។"

- បញ្ញត្តិទូទៅសម្រាប់កិច្ចដំណើរការនីតិវិធីរបស់អង្គបុរេជំនុំជម្រះទាំងនេះ គ្មានការកម្រិតជាក់លាក់ណាមួយពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង/ឬក៏ភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ។ លើសពីនេះទៅទៀត គេគួរបកស្រាយបញ្ញត្តិទាំងនេះដោយយោងទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[២]។

- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្មីដែលបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មានចែងត្រង់មាត្រា ២៥៨ ដំណឹងអំពីកាលបរិច្ឆេទនៃសវនាការនេះត្រូវជូនដល់ជនត្រូវចោទ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងដល់មេធាវី[៣]។

- ទាក់ទងនឹងការបង្ហាញខ្លួនក្នុងសវនាការ ក្រមថ្មីនេះ ត្រង់មាត្រា ២៦០(៣) ចាត់ភារកិច្ចឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចថាតើគម្បីបង្គាប់ឱ្យគូភាគីចូលមកបង្ហាញខ្លួន "រួមទាំងជនត្រូវ

ចោទជាប់ឃុំ" ផងឬយ៉ាងណា។ ដូច្នេះមានន័យថា ក្រមកម្ពុជាផ្តល់លទ្ធភាពដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ។

- វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា "វិធានផ្ទៃក្នុងត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ" និងចែងបន្តក្នុងវិធាន ២១(១)(ក) ថា "ដំណើរការនីតិវិធីត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។

១០- អាស្រ័យហេតុនេះ ទោះបីជាវិធានផ្ទៃក្នុងមិនបានចែងជាពិសេសអំពីការបង្ហាញខ្លួនរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គបុរេជំនុំជម្រះយ៉ាងណាក៏ដោយ ក៏ការបង្ហាញខ្លួននេះវាមានភាពស្របគ្នាទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាធម្មតាផងដែរ។

១១- គ្មានការកម្រិតជាក់លាក់ណាមួយមានចែងក្នុងវិធានផ្ទៃក្នុងអំពីថាតើសវនការជាក់លាក់ ឬកិច្ចដំណើរការនីតិវិធីកំណត់ណាមួយដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមបាននោះទេ។ ដូចគ្នាដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានដាក់កម្រិតលើសវនាការ ឬកិច្ចដំណើរការនីតិវិធីណាមួយដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមទេ[៤]។ បន្ថែមលើនេះទៀត ក្នុងនាមជា "គូភាគី" នៃកិច្ចដំណើរការនីតិវិធី គេមិនឃើញមានកាតព្វកិច្ចណាមួយដែលតម្រូវថាភាគីណាដែលទទួលបានឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែដាក់ពាក្យសុំសិទ្ធិចូលរួមជាក់លាក់ណាមួយពាក់ព័ន្ធនឹងសវនាការពិសេសណាមួយពី អ.វ.ត.ក នោះទេ។ ចំណុចនេះវាស្របគ្នាទៅនឹងវិធាន ២៣(៤) នៃវិធានផ្ទៃក្នុងដែលចែងថា:

> "៤. ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលបើកសវនាការ។ ពាក្យបណ្តឹងនេះត្រូវធ្វើជាលាយល័ក្ខអក្សរ ប្រគល់ឱ្យក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង និងត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី។ ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលស៊ើបសួរ មិនតម្រូវឱ្យដាក់ពាក្យជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះឡើយ"។ [បានបញ្ជាក់បន្ថែមទៀត]

១២- លទ្ធភាពសម្រាប់ឱ្យជនរងគ្រោះបានចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ក៏ទទួលទទួលស្គាល់ផងដែរនូវភាពស្របគ្នានៃការផ្តល់ឱកាសដល់ជនរងគ្រោះក្នុងការបញ្ចេញមតិកង្វល់ និងទស្សនៈផ្សេងៗរបស់ខ្លួនដោយផ្ទាល់។

១៣- ម៉្យាងវិញទៀត ការផ្តល់លទ្ធភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ គឺបម្រើផលប្រយោជន៍ឱ្យដល់គោលបំណងជាក់លាក់មួយក្នុងការផ្តល់លទ្ធភាពឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវទស្សនៈ និងកង្វល់របស់ខ្លួនស្តីពីបញ្ហាទាំងឡាយដែលទាក់ទិននឹងការឃុំខ្លួន ក៏ដូចជាបញ្ហាមួយចំនួនទៀតដែលពាក់ព័ន្ធនឹងផលប៉ះពាល់ទៅលើការការពារ និងសន្តិសុខរាងកាយ និងផ្លូវចិត្តរបស់ពួកគាត់ បញ្ហាព័ត៌មានស្តីពីការសម្លុតបំភ័យ ឬការសងសឹក និងចំណុចសំខាន់ៗមួយចំនួនទៀតដូចមានចែងក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ប្រសិនបើមានការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។

១៤. ការលើកជាដដែលៗអំពីគោលបំណងខាងលើទាំងនេះ គឺជាគោលបំណងក្នុងការទទួលស្គាល់នូវវិភាគទានយ៉ាងសំខាន់មួយដែលបុគ្គលម្នាក់ៗអាចបរិច្ចាកក្នុងការយកលាតត្រដាងក្នុងកិច្ចដំណើរការនីតិវិធី អំពីអ្វីដែលជាការជួបប្រទះដោយផ្ទាល់របស់គាត់ចំពោះបទឧក្រិដ្ឋទាំងនោះ។ ជនរងគ្រោះអាចដឹងយ៉ាងច្បាស់អំពីឧក្រិដ្ឋកម្មដែលបានកើតឡើង ហើយលទ្ធភាពរបស់ពួកគេក្នុងការចូលរួមក្នុងនីតិវិធីនោះគឺការអាចបញ្ចូលបន្ថែមនូវព័ត៌មានទាំងឡាយដែលអាចយកមកប្រើប្រាស់បានសម្រាប់ជាផលប្រយោជន៍ដល់អង្គបុរេជំនុំជម្រះ។ករណីនេះអាចជួយជាសំខាន់ដល់ខាងសហព្រះរាជអាជ្ញា។ ជាពិសេស ករណីនេះមានសារៈសំខាន់ក្នុងដំណាក់កាលដំបូងៗនៃការស៊ើបអង្កេត ព្រោះដំណាក់កាលដំបូងៗនៃការស៊ើបអង្កេតនេះ វានឹងជះឥទ្ធិពលយូរអង្វែងទៅដល់កិច្ចដំណើរការនីតិវិធីទៅអនាគត។ ការអនុញ្ញាតបញ្ចូលមតិយោបល់របស់ជនរងគ្រោះនៅក្នុងដំណាក់កាលដំបូងៗនេះនឹងជួយ អ.វ.ត.ក ឱ្យជៀសផុតពីការប្រឈមមុខមួយចំនួន ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិពិសេសៗដូចគ្នានេះធ្លាប់ជួបប្រទះកន្លងមក ជាពិសេសពាក់ព័ន្ធនឹងការចោទប្រកាន់ដំបូងៗដែលមានលក្ខណៈរឹតត្បិត ព្រោះគេច្រើនតែមិនរាប់បញ្ចូលបទឧក្រិដ្ឋសំខាន់ៗមានដូចជា ការរំលោភបំពានលើផ្លូវភេទជាដើម ដែលទាំងនេះគឺកត្តាសំខាន់ដែលបង្កើតឱ្យមានបទឧក្រិដ្ឋទាំងនោះកើតឡើង។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសរ្វាន់ដា ប្រសិនបើព្រះរាជអាជ្ញាបានអនុញ្ញាតឱ្យជនរងគ្រោះបានថ្លែងអំពីកង្វល់របស់ពួកគាត់អំពីការរំលោភបំពានផ្លូវភេទ នៅក្នុងដំណាក់កាលដំបូងៗនៃកិច្ចដំណើរការនីតិវិធី

នោះម្ល៉េះសមពួកគាត់មិនចាំបាច់អ្វីត្រូវដកដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងត្រូវធ្វើការកែប្រែដីកាសន្និដ្ឋានលើកទីមួយនោះឡើយ។ ការដែលមិនបានអនុញ្ញាតឱ្យជនរងគ្រោះចូលរួមពីដំបូងក្នុងសំណុំរឿងក្តី អាកាយេហ្សូ នេះហើយ ទើបធ្វើឱ្យមានការដាក់សម្ពាធយ៉ាងច្រើនពីអង្គការមិនមែនរដ្ឋាភិបាលដែលស្នើឱ្យព្រះរាជអាជ្ញាធ្វើការដក និងកែប្រែដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនោះ។ ដូចគ្នានេះដែរ ការដែលគ្មានជនរងគ្រោះអនុញ្ញាតឱ្យចូលរួមនៅក្នុងតុលាការពិសេសនៃប្រទេស សេរ៉ាឡេអូន ធ្វើឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះលើដំបូងរបស់ព្រះអាជ្ញាប្រឆាំងលើកក្រុមកងកម្លាំង CDF គ្មានបញ្ចូលនូវឧក្រិដ្ឋកម្មដែលទាក់ទងទៅនឹងការរំលោភបំពានលើផ្លូវភេទផងទេ។ បួនខែមុនការចាប់ផ្តើមអង្គសវនាការ ព្រះរាជអាជ្ញាបានស្វះស្វែងធ្វើវិសោធនកម្មលើដីកានោះ ដើម្បីបានបញ្ចូលបទចោទមួយចំនួនទៀតដែលទាក់ទងទៅនឹងការចាប់រំលោភ ទាសករផ្លូវភេទ ទង្វើរអមនុស្សធម៌ដ៏ទៃទៀតដូចជាការរៀបការដោយបង្ខំ និងការបំពានទាំងឡាយទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គលជាដើម[៥]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានបដិសេធចំពោះការសុំអនុញ្ញាតឱ្យធ្វើវិសោធនកម្មទៅលើដីកានោះ ដែលជាលទ្ធផលធ្វើឱ្យមានការ “បំបិទមាត់” ជនរងគ្រោះនៃអំពើរំលោភបំពានលើផ្លូវភេទមិនឱ្យមានសម្លេងក្នុងការជំនុំជម្រះក្តីនោះ[៦]។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាក្នុងការព្យួរការស៊ើបអង្កេតបន្ថែមទៅលើបទចោទថ្មីៗបន្ថែមទៀតប្រឆាំងនឹង Thomas Lubanga Dyilo ដោយត្រូវរង់ចាំរហូតដល់មានការបញ្ជាក់ច្បាស់អំពីសវនាការជាមុនសិននេះ គឺធ្វើឡើងដោយសារតែវាមានបញ្ហាពាក់ព័ន្ធទៅនឹងពាក្យសុំចូលរួមក្នុងរឿងក្តីប្រឆាំងនឹង Thomas Lubanga Dyilo ដែលតុលាការតម្រូវឱ្យដាក់ពាក្យនេះបាន លុះត្រាតែជនអ្នកដាក់ពាក្យមានជាប់ពាក់ព័ន្ធនឹងនឹងបទចោទក្នុងពេលឥឡូវនេះ។ ប្រសិនបើពិតដូចអញ្ចឹងមែន ការសម្រេចបែបនេះ គឺគួសបញ្ជាក់យ៉ាងច្បាស់អំពីសារៈសំខាន់នៃការចូលរួមរបស់ជនគ្រោះក្នុងដំណាក់កាលដំបូងៗនៃកិច្ចដំណើរការនីតិវិធី។

១៥. ការដែលច្បាប់ ឬវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបានផ្តល់ជាពិសេសនូវសិទ្ធិទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមក្នុងសវនាការនៃអង្គបុរេជំនុំជម្រះ មិនមែនជាបញ្ហាដែលរាំងខ្ទប់មិនឱ្យពួកគេចូលរួមបាននោះទេ ត្បិតអីពួកគេបានត្រូវទទួលស្គាល់ជាគូភាគីក្នុងកិច្ចដំណើរការនីតិវិធីទាំងមូលរួចទៅហើយ។ សូម្បីតែក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ បើទោះជាមានការរឹតត្បិតច្រើនជាងនៅ អ.វ.ត.ក ចំពោះលទ្ធភាពចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីក៏ដោយ (នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនោះ ជនរងគ្រោះមិនមែនជា “គូភាគី” ក្នុងកិច្ចដំណើរការ

នីតិវិធីទេ) ក៏តុលាការបានទទួលស្គាល់ថាការចូលរួមគឺអាចអនុវត្តបានជាទូទៅក្នុងកិច្ចដំណើរការនីតិវិធីទាំងឡាយ ដូចមានចែងក្នុងមាត្រា ៦៨(៣) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយមិនសិទ្ធិចូលរួមនេះគឺគ្មានព្រំដែនកំណត់ទេ ពោលគឺប្រសិនបើមានចែងជាពិសេសអំពីសិទ្ធិចូលរួមនេះ[៩]។ ជាបន្ថែមទៀត បញ្ញត្តិ ៨៦(៨) នៃបទប្បញ្ញត្តិរបស់តុលាការ ទាក់ទងទៅនឹងការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធី ចែងថា “សេចក្តីសម្រេចណាមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះនៅក្រោមមាត្រា ៨៩ [នៃវិធាននីតិវិធី និងភស្តុតាង ICC-ASP/1/3] នឹងត្រូវយកអនុវត្តបានចំពោះគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ក្នុងករណីដូចគ្នានេះ”។

១៦. ដោយសារមានការទាក់ទងគ្នាយ៉ាងពិតប្រាកដ និងយ៉ាងសំខាន់រវាងសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះ និងការស្ម័គ្រចិត្តរបស់ពួកគេ ក្នុងការចូលមកតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ការដែលផ្តល់ការអនុញ្ញាតឲ្យពួកគេមានលទ្ធភាពចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺជួយឲ្យសម្រេចបានគោលបំណងរួមនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងក្នុងវិធាន ២៣ និងក្នុងកថាខណ្ឌ ១៤ ខាងលើ។

**លទ្ធភាពក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការ នីតិវិធីពីដំបូងៗ របស់ អ.វ.ត.ក រួមមានកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបណ្តឹង ឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺមានភាពស្របគ្នានឹងបទដ្ឋាន និងការអនុវត្តន៍របស់ជាតិ និងអន្តរជាតិ៖**

**<u>បទដ្ឋានជាតិ-</u>**

១៧. លទ្ធភាពឲ្យជនរងគ្រោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមានការប្រែប្រួលខុសគ្នាច្រើនពីប្រទេសមួយទៅប្រទេសមួយ វាអាស្រ័យទៅតាមទម្លាប់នៃការអនុវត្តន៍ច្បាប់ជាប្រពៃណីរបស់ប្រទេសទាំងនោះ។ ដូចនៅប្រទេសកម្ពុជាដែលមានទម្លាប់អនុវត្តតាមប្រព័ន្ធច្បាប់ Civil Law ឬប្រព័ន្ធ “ប្រើការជជីកសួរហេតុផលដោយចៅក្រម [inquisitorial]” លទ្ធភាពឲ្យជនរងគ្រោះចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីជាការធម្មតា។ ដូច្នេះហើយនៅក្នុងប្រទេសកម្ពុជា ជនរងគ្រោះបានត្រូវ

ទទួលស្គាល់ថាជាគូភាគីក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដោយត្រូវបានទទួលនូវសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នេះ។

១៨. ក្នុងន័យទូទៅ ចំពោះប្រទេសមួយចំនួនដែលឲ្យជនរងគ្រោះមានលទ្ធភាពចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី គឺបានអនុញ្ញាតឲ្យមានការចូលរួមនេះនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ រួមទាំងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នផង។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការកំណត់ព្រំដែននៃការចូលរួមជាក់លាក់មួយចំនួនទៅលើគូភាគីក្នុងការដែល *ចង់ធ្វើ*បណ្តឹងឧទ្ធរណ៍ (ខុសពីការ *ចូលរួម* ក្នុងកិច្ចដំណើរការនីតិវធីនៃបណ្តឹងឧទ្ធរណ៍) ដូចក្នុងប្រទេសកម្ពុជា មានករណីជាច្រើនដែលតុលាការមិនអនុញ្ញាតសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះទេ។ ប៉ុន្តែករណីនេះមិនបានរាំងពួកគេមិនឲ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួននេះឡើយ។ ជាបន្ថែមទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលនីតិវិធីព្រហ្មទណ្ឌកម្ពុជាយកជាមូលដ្ឋាន ដូចចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ត្រូវមានការជូនដំណឹងអំពីកាលបរិច្ឆេទមុនសវនាការនៅអង្គបុរេជំនុំជម្រះតាមរយៈអគ្គព្រះរាជអាជ្ញាទៅ “ភាគីនិមួយៗ និងមេធាវីរបស់ពួកគេ”។ ទាក់ទងនឹងសវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ (Chambre d'instruction) មាត្រាថ្មី ១៩៩(២) នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងថា ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន សវនាការនោះត្រូវធ្វើជាសាធារណៈ លើកលែងតែព្រះរាជអាជ្ញា ជនត្រូវចោទ ឬ “ភាគីរដ្ឋប្បវេណី” ស្នើសុំឲ្យធ្វើជាសម្ងាត់ចាប់តាំងពីចាប់ផ្តើមសវនាការ។ អត្ថន័យនៃមាត្រាថ្មីនេះ រួមទាំងការប្រតិបត្តិជាប្រចាំនៅចំពោះមុខតុលាការបារាំង ធ្វើឲ្យមានសេចក្តីសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងចូលរួមស្តាប់សវនាការ ទោះបីជានៅក្នុងកម្ពុជា ឬនៅចំពោះមុខ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងឧទ្ធរណ៍ទៅតុលាការកំពូល (Cour de Cassation) ជំទាស់សេចក្តីសម្រេចណាមួយទាក់ទងទៅនឹងការឃុំខ្លួនរបស់ជនត្រូវចោទទេ។

១៩. ទោះជានៅក្នុងប្រទេសដែលអនុវត្ត Common Law ដែលមិនមានប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី ក៏មានបញ្ជាក់ជារឿយៗនូវការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការពិនិត្យមើលយន្តការដើម្បីជំទាស់នឹងសេចក្តីសម្រេចរបស់រដ្ឋជម្រះសេចក្តី ឬលើកលែងចោទប្រកាន់ករណីណាមួយ។ ការធ្វើបែបនេះគឺដើម្បីផ្តួចផ្តើមឱ្យមានកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅពេលដែលរដ្ឋបដិសេធមិនព្រមធ្វើការជម្រះសេចក្តី ឬបើមិនអញ្ជើញទេភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមក្នុង

នាមជាឯកជន ឬព្រះរាជអាជ្ញាបន្ទាប់បន្សំក្នុងអំឡុងកិច្ចស៊ើបអង្កេត និងក្នុងអំឡុងពេលជំនុំជម្រះ។ ជាបន្ថែមទៀត យុត្តាធិការមួយចំនួនទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលការជូនដំណឹងអំពីការដោះលែងចុងចោទពីការឃុំខ្លួនដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយត្រូវបង្ហាញខ្លួន និងធ្វើសក្ខីកម្មនៅសវនាការអំពីការឃុំខ្លួន។

## <u>បទដ្ឋានអន្តរជាតិ</u>

២០. បទដ្ឋានអន្តរជាតិទទួលស្គាល់ភាពទាក់ទងគ្នា និងសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីទាំងមូល ដោយអះអាងនូវសិទ្ធិចូលរួមក្នុងនីតិវិធីរបស់ជនរងគ្រោះទាក់ទងនឹងការចោទប្រកាន់។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការប្រើប្រាស់អំណាចខុស តម្រូវថា "ទស្សនៈ និងកង្វល់របស់ជនរងគ្រោះ ត្រូវតែបានយកមកពិចារណា ក្នុងកិច្ចដំណើរការនីតិវិធីដែលសមស្រប នៅពេលណាដែលកិច្ចដំណើរការនីតិវិធីនោះប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគាត់"[១៧]។ គោលការណ៍ និងការណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិ និងសំណងសម្រាប់ជនរងគ្រោះពីការរំលោភធ្ងន់ធ្ងរនៃច្បាប់ សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ ទទួលស្គាល់ថាសិទ្ធិទទួលសំណងរបស់ជនរងគ្រោះរួមមាន "ការទទួលបានយុត្តិធម៌ស្មើគ្នា និងមានប្រសិទ្ធិភាព"។ សន្ធិសញ្ញា និងបទដ្ឋានអន្តរជាតិដ៏ទៃទៀតដែលសំដៅជាពិសេសសិទ្ធិចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមមាន៖ *ពិធីសារក្នុងការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ* សេចក្តីសម្រេចចិត្តទុកកុមារជាជនរងគ្រោះ និងជនដែលដល់ ដែលផ្តល់អនុសាសន៍ថា៖ "...រដ្ឋទាំងឡាយ ក្នុងលក្ខណៈស៊ីសង្វាក់គ្នាជាមួយសិទ្ធិចូលរួមក្នុងនីតិវិធីនៃច្បាប់ជាតិ និងរដ្ឋបាលតុលាការ ទាក់ទងនឹងករណីកុមារ នឹងអាចឲ្យកុមារចូលរួម តាមករណីសមស្រប ក្នុងកិច្ចដំណើរការនីតិវិធីតុលាការព្រហ្មទណ្ឌ មានការស្តាប់កុមារ ការផ្តល់ព័ត៌មានដល់កុមារអំពីស្ថានភាពរបស់ពួកគេ និងកិច្ចដំណើរការនីតិវិធីណាមួយដែលអាចមានបន្តបន្ទាប់មកទៀត រួមមានដំណាក់កាលស៊ើបអង្កេត និងក្នុងអំឡុងពេលទាំងអស់នៃការកាត់សេចក្តី និងក្រោយការកាត់សេចក្តី" *គោលការណ៍ទាំងឡាយនៃការស៊ើបអង្កេតដែលមានប្រសិទ្ធិភាព និងឯកសារទាក់ទងនឹងទារុណកម្ម និងប្រព្រឹត្តកម្មឃោរឃៅអមនុស្សធម៌ ឬនាំឲ្យអាម៉ាស់មុខ ឬការដាក់ទណ្ឌកម្ម* និងសេចក្តីសម្រេចលើគម្រោងរបស់ក្រុមប្រឹក្សា

នៃសហព័ន្ធអឺរ៉ុប *ដើម្បីធ្វើឲ្យស្ថានភាពរបស់ជនរងគ្រោះមានភាពប្រសើរឡើងក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។*

## តុលាការក្នុងតំបន់

២១. តុលាការក្នុងតំបន់ក៏បានទទួលស្គាល់ដែរនូវសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងនីតិវិធីក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ តុលាការអន្តរអាមេរិកាំងស្តីពីសិទ្ធិមនុស្សក៏បានទទួលស្គាល់ដែរ ដូចជាសិទ្ធិក្នុងការកាត់សេចក្តីមិនលម្អៀង បានសេចក្តីថាសិទ្ធិរបស់គ្រួសារជនរងគ្រោះត្រូវមានការធានាផ្នែកផ្លូវច្បាប់ និងជាពិសេសឲ្យមានការស៊ើបអង្កេតឧក្រិដ្ឋកម្មក្នុងគោលបំណងរកអត្តសញ្ញាណ និងក្នុងករណីសមស្រប ធ្វើការចោទប្រកាន់ និងដាក់ទណ្ឌកម្មលើអ្នកដែលទទួលខុសត្រូវទាំងនោះ។ ព្រមគ្នានោះដែរ តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សក៏បានទទួលស្គាល់ដែរថាក្នុងគ្រប់ករណីទាំងអស់ "ត្រូវតែមានធាតុផ្សំនៃការពិនិត្យពិច័យគ្រប់គ្រាន់លើការស៊ើបអង្កេត ឬលើលទ្ធផលនៃការស៊ើបអង្កេតគ្រប់គ្រាន់ពីសាធារណៈជន ដើម្បីធានានូវការទទួលខុសត្រូវទាំងទៅលើការអនុវត្តន៍ទាំងទៅលើទ្រឹស្តី។ កម្រិតចាំបាច់នៃការពិនិត្យពិច័យរបស់សាធារណៈជនអាចប្រែប្រួលពីករណីមួយទៅករណីមួយ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងគ្រប់ករណីទាំងអស់ សាច់ញាតិដែលជិតជាងគេរបស់ជនរងគ្រោះត្រូវតែមានការពាក់ព័ន្ធក្នុងនីតិវិធីរហូតដល់ចំណុចមួយដែលចាំបាច់ក្នុងការការពារផលប្រយោជន៍ដែលត្រឹមត្រូវតាមច្បាប់"។ តុលាការអឺរ៉ុបផ្នែកសិទ្ធិមនុស្សបានកត់សម្គាល់បន្ថែមថា សិទ្ធិទទួលបាននូវការជំនុំជម្រះមិនលម្អៀង "រួមមានសិទ្ធិរបស់ភាគីដែលចូលរួមក្នុងសវនាការ ក្នុងការដាក់ជូននូវសេចក្តីសន្និដ្ឋានណាមួយដែលពួកគេយល់ថាមានសារៈសំខាន់សម្រាប់សំណុំរឿងរបស់ពួកគេ។ គោលការណ៍របស់អនុសញ្ញានេះ គឺចង់ធានាឲ្យបាននូវសិទ្ធិ មិនគ្រាន់តែធានាក្នុងទ្រឹស្តី ឬជាការបំភាន់ភ្នែកទេ តែត្រូវធានាក្នុងការអនុវត្តន៍មួយដែលប្រកបដោយប្រសិទ្ធិភាពផងដែរ"។

## តុលាការព្រហ្មទណ្ឌអន្តរជាតិ

២២. តុលាការព្រហ្មទណ្ឌអន្តរជាតិជាយុត្តាធិការព្រហ្មទណ្ឌអន្តរជាតិតែមួយគត់ដែលអនុញ្ញាតឲ្យជនរងគ្រោះមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ក្នុងតួនាទីមិនត្រឹមតែជាសាក្សីនៃ

ឧក្រិដ្ឋកម្មប៉ុណ្ណោះទេ តែអនុញ្ញាតឱ្យពួកគាត់ដើរតួបម្រើផលប្រយោជន៍ឯករាជ្យភាពរបស់ខ្លួនបានទៀតផង។ មាត្រា ៦៨(៣) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា៖

> “៣. ក្នុងករណីដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះបានត្រូវប៉ះពាល់ តុលាការត្រូវអនុញ្ញាតឱ្យពួកគេបញ្ចេញទស្សនៈ និងកង្វល់របស់ពួកគេដែលនឹងត្រូវយកមកពិចារណានៅដំណាក់កាលផ្សេងៗនៃកិច្ចដំណើរការនីតិវិធីឱ្យបានសមរម្យក្នុងលក្ខណៈមួយដែលមិនធ្វើឱ្យខូចប្រយោជន៍ ឬដែលមិនផ្ទុយគ្នាពីសិទ្ធិរបស់ជនជាប់ចោទ និងត្រូវជំនុំជម្រះដោយយុត្តិធម៌ និងមិនលម្អៀង។ ទស្សនៈ និងកង្វល់ទាំងនេះនឹងត្រូវបង្ហាញដោយតំណាងពេញច្បាប់របស់ជនរងគ្រោះដែលតុលាការចាត់ថាសមស្រប ដោយអនុលោមទៅតាមបទបញ្ញត្តិនៃនីតិវិធី និងភស្តុតាង។

មាត្រា ៦៨(៣) ជាបទបញ្ញត្តិមួយដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។

២៣. បន្ថែមលើបទបញ្ញត្តិទូទៅពាក់ព័ន្ធនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ក៏ដូចជាតុលាការឯទៀតដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់សិទ្ធិឱ្យជនរងគ្រោះចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងការតម្រូវឱ្យទទួលយក ឬកែប្រែដីកាបង្គាប់ឱ្យឃុំខ្លួននានា។ វិធាន ១១៩(៣) នៃវិធាននីតិវិធីនិងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា:

> “មុននឹងដាក់កម្រិតឱ្យទទួលយក ឬកែប្រែលក្ខខណ្ឌណាមួយដែលរឹតត្បិតដល់សិទ្ធិសេរីភាព អង្គបុរេជំនុំជម្រះត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា ពីសាមីជន ពីរដ្ឋដែលពាក់ព័ន្ធ និងពីបណ្តាជនរងគ្រោះដែលបានទាក់ទងគ្នាជាមួយតុលាការនៅក្នុងរឿងក្តីនោះ រួមទាំងបុគ្គលទាំងឡាយណាដែលតុលាការយល់ឃើញថាអាចមានហានិភ័យដោសារតែការដោះលែង ឬដោយសារតែលក្ខខណ្ឌតម្រូវទាំងនោះ។”

២៤. ចំពោះបញ្ហានៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងការប្តឹងឧទ្ធរណ៍ជំទាស់ដីកាបង្គាប់ឱ្យឃុំខ្លួននោះ គឺត្រូវបានលើកយកមកពិចារណាជាពិសេសទាក់ទង

នឹងរឿងក្តីប្រឆាំងនឹងលោក Thomas Lubanga Dyilo។ នៅក្នុងសាលដីកានៃបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី១ ដែលមានចំណងជើងថា "*Deciison sur la demande de mise enliberte proviosoir de Thomas Lubanga Dyilo*",[27] អង្គជំនុំជម្រះឧទ្ធរណ៍បានកំនត់ថា ការចូលរួមរបស់ជនរងគ្រោះក្នុងបណ្តឹងឧទ្ធរណ៍ក្រោមមាត្រា ៨២ (l) (ខ) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះត្រូវដាក់ពាក្យសុំអនុញ្ញាតដើម្បីចូលរួមក្នុងបណ្តឹងឧទ្ធរណ៍នេះ។ ពាក្យសុំអនុញ្ញាតដើម្បីចូលរួមក្នុងបណ្តឹងឧទ្ធរណ៍របស់ជនរងគ្រោះដែលអនុលោមតាមមាត្រា ៨២ (l) (ខ)នៃលក្ខន្តិកៈនេះ គួរដាក់បញ្ចូលនូវសេចក្តីប្រកាសមួយដែលក់ព័ន្ធនឹងថា តើបណ្តឹងឧទ្ធរណ៍មួយនេះជះឥទ្ធិពលយ៉ាងណាខ្លះដល់ផលប្រយោជន៍ របស់ពួកគាត់និងបញ្ជាក់អំពីមូលហេតុអ្វីដែលធ្វើឱ្យអង្គជំនុំជម្រះឧទ្ធរណ៍គួរតែអនុញ្ញាតឱ្យពួកគាត់បានចូលរួមដើម្បីបង្ហាញជូននូវកង្វល់ និងទស្សនៈរបស់ពួកគាត់។ អង្គជំនុំជម្រះឧទ្ធរណ៍យល់ឃើញថា តម្រូវការនេះគឺបានមកពីពាក្យពេចន៍ដែលបានចែងយ៉ាង ច្បាស់នៅក្នុងមាត្រា ៦៨ (៣) របស់លក្ខន្តិកៈ។[28] បទបញ្ញត្តិនេះមានលក្ខណៈតឹងរ៉ឹងជាង នីតិវិធីសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ត្បិតអីគេមិនទទួលស្គាល់ជនរងគ្រោះថាជា "គូភាគី" នៅក្នុងកិច្ចដំណើរការនីតិវិធីទេ ហើយវាឆ្លុះបញ្ចាំងឱ្យឃើញនូវតុល្យភាពពិសេសរវាងទំនៀមទំលាប់នៃប្រព័ន្ធច្បាប់ Civil Law និង Common Law ដែលមានជាក់ស្តែងក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដោយហេតុថាគេទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីថាជា "គូភាគី" ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៃក្របខណ្ឌរបស់ អ.វ.ត.ក ដូច្នេះគេមិនចាំបាច់តម្រូវអោយពួកគាត់រៀបចំពាក្យសុំដោយឡែកពីគ្នា ដើម្បីបង្ហាញពីទស្សនៈ និងកង្វល់របស់ពួកគាត់នៅក្នុងសវនាការជាក់លាក់ណាមួយឡើយ។ តាមពិតទៅ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ក៏បានបកស្រាយថានៅពេលដែលអ្នកដាក់ពាក្យសុំណាម្នាក់ ត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ អ្នកនោះឯងនឹងមិនចាំបាច់ដាក់ពាក្យសុំសម្រាប់ដំណាក់កាលក្រោយៗមកទៀតនៃកិច្ចដំណើរការនីតិវិធីនេះទៀតទេ។ [29]

00166482



២៥. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ដូចបានរៀបរាប់ពីខាងដើម អង្គជំនុំជម្រះឧទ្ធរណ៍បានកត់សំគាល់ដូចខាងក្រោម:

> "អង្គជំនុំជម្រះឧទ្ធរណ៍មិនយល់ឃើញដូចក្នុងសារណារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងថា ជនរងគ្រោះគ្មានសិទ្ធិណាមួយចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការសម្រេចអំពីរឿងថាតើគួរដោះលែងជនដែលតុលាការចេញដីកាបង្គាប់ឱ្យនាំខ្លួនឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នទោះទេ។ បើទោះបីថា វិធាន ១១៨ ពិតជាមិនបានចែងអំពីអ្វីដែលជាក់លាក់សំដៅទៅរកជនរងគ្រោះក៏ដោយ ក៏អង្គជំនុំជម្រះឧទ្ធរណ៍បានចាត់ទុកបទបញ្ញត្តិនៃមាត្រា ៦៨ (៣) ថាបានផ្តល់លទ្ធភាពអោយអង្គជំនុំជម្រះឧទ្ធរណ៍ក្នុងការអនុញ្ញាតអោយជនរងគ្រោះបានបង្ហាញនូវទស្សនៈ និងកង្វល់របស់ពួកគាត់បាន នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើខ្លួនយល់ឃើញថាសមស្រប។
>
> អង្គបុរេជំនុំជម្រះក៏មិនទទួលយកសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងថា ប្រសិនបើតុលាការអនុញ្ញាតឱ្យជនរងគ្រោះចូលរួមដែរ នោះនឹងធ្វើឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវប្រឈមជាមួយព្រះរាជអាជ្ញាដល់ទៅពីរ។ ជាគោលការណ៍ជនរងគ្រោះអាចចូលរួមបាន ប្រសិនបើមានការប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់របស់ពួកគាត់ និងប្រសិនបើអង្គជំនុំជម្រះឧទ្ធរណ៍យល់ឃើញថាការចូលរួមរបស់ពួកគាត់មានលក្ខណៈសមស្រប។ វាគឺជាភារកិច្ចរបស់អង្គជំនុំជម្រះឧទ្ធរណ៍ដែលត្រូវធានាថា ការចូលរួមដោយមធ្យោបាយណាមួយក៏ដោយរបស់ពួកគាត់ នឹងមិនត្រូវឱ្យខូចប្រយោជន៍ ឬផ្ទុយគ្នាទៅនឹងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីមួយដោយយុត្តិធម៌ និងឥតលំអៀងឡើយ។ ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះឧទ្ធរណ៍មិនបានចាត់ទុកថា ការចូលរួមរបស់ជនរងគ្រោះក្នុងកិច្ចដំណើការនីតិវិធីនេះគឺជាការប្រឆាំងនឹងគោលការណ៍ទាំងអស់នោះទេ.."[30]

ដូច្នេះ អង្គជំនុំជម្រះឧទ្ធរណ៍បានសម្រេចថា ការចូលរួមរបស់ជនរងគ្រោះក្នុងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាបង្គាប់ឱ្យឃុំខ្លួននោះ ជាគោលការណ៍គឺគ្មានអ្វីដែលថាមិនសមស្របទេ។

ជាការពិតណាស់ អង្គជំនុំជម្រះឧទ្ធរណ៍បានអនុញ្ញាតអោយជនរងគ្រោះចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ចាត់របៀបស្តីពីការឃុំខ្លួននោះ បើទោះបីជាអង្គជំនុំជម្រះឧទ្ធរណ៍មិនបានរកឃើញអ្វីក្នុងសារណារបស់ជនរងគ្រោះដើម្បីយកមកជួយក្នុងការកំនត់មូលហេតុជាក់លាក់ចំពោះមុខអង្គជំនុំជម្រះឧទ្ធរណ៍យ៉ាងណាក៏ដោយ។ ក្នុងវាក្យខណ្ឌ ៦៩ ដល់ ៧២ នៃសាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ដូចមានរៀបរាប់ពីខាងលើ អង្គជំនុំជម្រះឧទ្ធរណ៍បានកំនត់ដូចតទៅនេះថា:

> "អង្គជំនុំជម្រះឧទ្ធរណ៍យោងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី១២ ខែធ្នូ ដែលសម្រេចផ្តល់អោយជនរងគ្រោះ នូវសិទ្ធិចូលរួមក្នុងការប្តឹងឧទ្ធរណ៍" ក្នុងគោលបំណងអោយជនរងគ្រោះបានបញ្ចេញនូវទស្សនៈ និងកង្វល់ដែលពាក់ព័ន្ធនឹងប្រយោជន៍ផ្ទាល់របស់ពួកគាត់ *ទាក់ទងនឹងបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍។"*
> (បញ្ជាក់បន្ថែម)

មានបញ្ហាជាក់លាក់ចំនួន៣ បានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងបណ្តឹងឧទ្ធរណ៍នោះ: (i) កាតព្វកិច្ចពិនិត្យម្តងម្កាលឡើងវិញនូវការឃុំខ្លួននៃជនសង្ស័យដោយអនុលោមតាមមាត្រា ៦០ (៣) នៃលក្ខន្តិកៈ (ii) អនុលោមតាមមាត្រា ៦០ (៤) នៃលក្ខន្តិកៈ ថាតើអង្គបុរេជំនុំជម្រះបានធ្វើការសម្រេចត្រឹមត្រូវដែរឬទេ ដែលថាម្ចាស់បណ្តឹងឧទ្ធរណ៍ពិតជាមិនត្រូវគេឃុំខ្លួនក្នុងរយៈពេលដែលមិនសមស្របណាមួយដោយសារតែព្រះអាជ្ញាបានធ្វើឲ្យមានការពន្យាពេលដែលមិនអាចប្រកែកបានណាមួយនោះ (iii) ថាតើអង្គបុរេជំនុំជម្រះបានយកកត្តាដែលមិនពាក់ព័ន្ធផ្សេងៗមកពិចារណា ឬក៏មានខកខានមិនបានអនុវត្តគោលការណ៍នៃភាពចាំនិងភាពសមាមាត្រ [the principles of necessity and proportionality] ដែរឬយ៉ាងណាក្នុងការសម្រេចលើរឿងដោះលែងម្ចាស់បណ្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្ននេះ។

ជនរងគ្រោះមិនបានបញ្ជាក់ច្បាស់ពីភាពទាក់ទងគ្នារវាងអ្វីដែលមានក្នុងសារណារបស់គាត់ និងបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ទេ។ កន្លងមកដោយសារកង្វល់របស់ជនរងគ្រោះ ត្រូវបានយកមកប្រើជាអំណះអំណាងក្នុងការ

ផ្តល់ជាភស្តុតាងដើម្បីគាំទ្រដល់ហេតុផលដែលមិនគួរដោះលែងអ្នកប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្ននោះ អង្គជំនុំជម្រះឧទ្ធរណ៍សម្រេចថា លក្ខណៈនៃបណ្តឹងឧទ្ធរណ៍នេះគឺត្រឹមត្រូវ និងគោរពទៅតាមហេតុផលជាក់លាក់ដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍។ នេះមិនមែនជាសវនាការសារថ្មីចំពោះការដោះលែងបណ្តោះអាសន្នលើបណ្តឹងដដែលនោះទេ។ ដោយសារហេតុផលដូច្នោះ ក្នុងបរិបទបណ្តឹងឧទ្ធរណ៍ក្នុងពេលបច្ចុប្បន្ននេះ វាពិតជាមិនសមស្របទេ ដែលត្រូវលើកឡើងដដែលម្តងទៀតអំពីភស្តុតាងដែលបានដាក់ជូនចំពោះមុខអង្គបុរេជំនុំជម្រះម្តងរួចហើយនោះ ហើយវាក៏មិនត្រឹមត្រូវដែរដែលត្រូវដាក់បង្ហាញនូវភស្តុតាងថ្មីមួយទៀតនៅចំពោះមុខអង្គជំនុំជម្រះឧទ្ធរណ៍ ប្រសិនជាគេមិនបានបង្ហាញឲ្យឃើញនូវភាពទាក់ទងគ្នាជាពិសេសណាមួយអំពីថាតើភស្តុតាងនោះវាប៉ះពាល់កម្រិតណាដល់ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះឧទ្ធរណ៍លើបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ទេនោះ។

យោងលើមូលហេតុទាំងឡាយខាងលើនេះ ស្របពេលដែលអង្គជំនុំជម្រះឧទ្ធរណ៍ទទួលស្គាល់នូវកង្វល់ដែលជនរងគ្រោះបានបង្ហាញពាក់ព័ន្ធជាមួយនឹងអ្វីដែលពួកគាត់អះអាងថាវាអាចនឹងកើតមានប្រសិនបើម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតុលាការដោះលែងបណ្តោះអាសន្ននោះក៏ដោយ ក៏អង្គជំនុំជម្រះឧទ្ធរណ៍មិនបានយកកង្វល់ទាំងនោះមកធ្វើជាជំនួយក្នុងការកំនត់នូវមូលហេតុជាក់លាក់នៅចំពោះមុខអង្គជំនុំជម្រះរបស់ខ្លួនក្នុងបណ្តឹងឧទ្ធរណ៍នាពេលបច្ចុប្បន្ននេះដែរ។ ដូច្នេះហើយទើបអង្គជំនុំជម្រះឧទ្ធរណ៍មិនបានពឹងផ្អែកលើកង្វល់ទាំងនោះ ក្នុងការសម្រេចទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នោះទេ។ នៅក្នុងស្ថានភាពបែបនោះ អង្គជំនុំជម្រះឧទ្ធរណ៍បានច្រានចោលនូវការឆ្លើយតបនានារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះបញ្ហាកង្វល់ទាំងនោះដោយជៀសមិនរួចផងដែរ។”[31]

ហេតុដូច្នេះ អង្គជំនុំជម្រះឧទ្ធរណ៍មិនត្រឹមតែបានអនុញ្ញាតអោយជនរងគ្រោះចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនរបស់លោក Thomas Lubanga ប៉ុណ្ណោះទេ តែខ្លួនក៏បានទទួលស្គាល់យ៉ាងច្បាស់ផងដែររាល់ក្តីកង្វល់ទាំងឡាយ ដែលជនរងគ្រោះបានលើកឡើង

នៅក្នុងបណ្តឹងឧទ្ធរណ៍នោះ។ ករណីដែលអង្គជំនុំជម្រះឧទ្ធរណ៍បានសម្រេចថាមិនពឹងផ្អែកលើកង្វល់នានារបស់ជនរងគ្រោះក្នុងការសម្រេចលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ គឺបណ្តាលមកពីមូលហេតុនៃលក្ខណៈពិសេសនៃដំណើរការនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនេះឯង ដែលវាមានលក្ខណៈត្រឹមត្រូវដូចដែលអង្គជំនុំជម្រះឧទ្ធរណ៍បានគូសបញ្ជាក់រួចហើយ និងដោយយោងតាមអង្គហេតុដែលថាទស្សនៈរបស់ជនរងគ្រោះមិនមានអ្វីទាក់ទងគ្នាទៅនឹងបញ្ហានានាដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍នោះទេ។ ទោះជាយ៉ាងនេះក្តី គេក៏មិនឃើញមានការរឹតត្បិតដល់សិទ្ធិជនរងគ្រោះក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ទាំងនេះនោះដែរ ជាពិសេសគឺក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួននេះឯង។

២៦. មកទល់ពេលបច្ចុប្បន្ននេះ មាត្រា៦៨ (៣) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបកស្រាយនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ដើម្បីផ្តល់លទ្ធភាពអោយជនរងគ្រោះ ចូលរួមក្នុងសកម្មភាពនានា នៅក្នុងដំណាក់កាលដំបូងៗនៃកិច្ចដំណើរការនីតិវិធី មុនពេលមានការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[32] និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនានាដែលពាក់ព័ន្ធនឹងការកំនត់បទចោទ។[33] អ្នកចូលរួមដែលជាជនរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងបញ្ចេញយោបល់ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យប្តឹងសុំដោះលែងដែលដាក់ប្តឹងដោយមេធាវីការពារក្តី។

**ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ មិនរំលោភសិទ្ធិការពារក្តីទេ**

២៧. មានការលើកឡើងថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ មិនត្រូវធ្វើអោយខូចប្រយោជន៍ដល់សិទ្ធិរបស់ជនត្រូវចោទ និងមិនត្រូវប៉ះពាល់ការជំនុំជម្រះក្តីដោយឥតលំអៀង និងដោយយុត្តធម៌នោះទេ។

២៨. ដោយពិចារណាលើករណីថាតើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើអោយខូចប្រយោជន៍ ឬផ្ទុយទៅនឹងសិទ្ធិរបស់ជនត្រូវចោទ និងប៉ះពាល់ដល់ការជំនុំជម្រះក្តីដែល

មិនលំអៀង និងដោយយុត្តិធម៌ដែរឬយ៉ាងណានោះ មានការស្នើជាយោបល់ថា អ.វ.ត.ក ត្រូវតែយកចិត្តទុកដាក់ឲ្យមែនទែន ដោយធ្វើយ៉ាងណាកុំឲ្យទស្សនៈ និងក្តីកង្វល់នានារបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ចាត់របៀបនេះ ពាក់ព័ន្ធជាមួយនឹងសិទ្ធិចូលរួមក្នុងនីតិវិធីទាំងឡាយណាដែលទាក់ទងគ្នានឹងបញ្ហាដែលឈានទៅរកភាពមានពិរុទ្ធភាព ឬភាពគ្មានទោសនៃជនសង្ស័យណាមួយ ឬជនត្រូវចោទណាម្នាក់ ឬក៏ការជឿទុកចិត្តរបស់សាក្សីដាក់បន្ទុកឡើយ។ លទ្ធភាពដែលអាចធ្វើអោយខូចប្រយោជន៍នេះ គឺជាបញ្ហាបរិបទទាំងស្រុង និងពាក់ព័ន្ធតែទៅលើករណីជាក់លាក់ ដោយផ្អែកលើបទចោទជាក់លាក់ និងភស្តុតាងដែលបានបង្ហាញជូន។ ដោយសារគ្មានអន្តរាគមន៍ជាក់លាក់ណាមួយ អាចបង្ហាញ និងបញ្ជាក់ឲ្យច្បាស់លាស់អំពីពិរុទ្ធភាពរបស់ជនត្រូវចោទទាក់ទងនឹងបទចោទជាក់ស្តែងនោះ គេដូចជារកមិនឃើញថាតើការធ្វើឲ្យខូចប្រយោជន៍នេះវាកើត ឡើងបានដោយរបៀបណានោះទេ។

២៩. កាលពីថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៧ ទាក់ទងនឹងស្ថានការណ៍នៅ Darfur អង្គបុរេជំនុំជម្រះ ទី១ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានកត់សំគាល់ថា:

> ក្រោមវិធាន ៨៦ (២) នៃវិធានរបស់តុលាការ: “នៅក្នុងស្ថានការណ៍ និងកិច្ចដំណើរការនីតិវិធីរឿងក្តីនៅចំពោះមុខអង្គបុរេជំនុំជម្រះ [...] អង្គហេតុដែលថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គលមួយឬច្រើន ដែលបានទទួលនូវឋានៈតាមនីតិវិធីរបស់ជនរងគ្រោះ គឺមិនធ្វើឲ្យខូចប្រយោជន៍ដល់ការការពារក្តីនោះទេ”[34]

៣០. ជាការពិត ដោយយោងលើឋានៈជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី លទ្ធភាពសម្រាប់អោយដើមបណ្តឹងរដ្ឋប្បវេណីអាចបង្ហាញទស្សនៈ និងក្តីកង្វល់របស់ខ្លួន គឺមានភាពសមស្រប និងស៊ីសង្វាក់ជាមួយនឹងការជំនុំជម្រះក្តីដោយមិនលំអៀង និងដោយយុត្តិធម៌ ដែលផ្តល់អោយមានការគោរព។ ការនេះមិនត្រឹមតែគោរពដល់សិទ្ធិការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែគឺវាផ្តល់ការគោរពចំពោះសិទ្ធិរបស់គ្រប់ភាគី រួមទាំងភាគីទាមទារសំណងរដ្ឋប្បវេណីផងដែរ។[35] នៅក្នុងស្ថានភាពជាក់លាក់មួយចំនួន វាជាការសមស្របដែល អ.វ.ត.ក ជ្រើសយក

C11/42

វិធានការណ៍ដើម្បីធានាថាចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីពិតជាប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធិភាព[36] ។ ប្រការនេះគឺជាបញ្ហានៃបែបផែននៃការចូលរួមសុទ្ធសាធ ដែលគេគួរតែយកមកពិចារណាទៅតាមរឿងក្តីដែលខុសគ្នាៗ នៅក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធ វាប្រសើរជាងការសម្រេចដាក់កំហិតតាំងតែពីដើមដំបូងមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមក្នុងគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់នោះ។ ការបដិសេធតាមអំពើចិត្តមិនអោយដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសក្នុងការបង្ហាញនូវទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួនក្នុងដំណាក់កាលដ៏សំខាន់ដែលប៉ះពាល់ផលប្រយោជន៍ផ្ទាល់របស់ពួកគេបែបនេះ គឺពិតជាប្រឆាំងទៅនឹងគោលការណ៍យុត្តិធម៌ និងភាពមិនលំអៀងពិតប្រាកដណាស់។

សូមដាក់ជូនខ្លឹមសារទាំងអស់ខាងលើ ដោយក្តីគោរព។

ជួសម្ចាស់សារណាទាំងអស់, REDRESS, FIDH និង ASF

*ហត្ថលេខា*

Carka Ferstmin, នាយកអង្គការ REDRESS

ទីក្រុងឡុងដ៍, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៨